អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន
# ពីសហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីសំណុំរឿង ០០៣

សហព្រះរាជអាជ្ញាអន្តរជាតិ Brenda J. Hollis ចេញសេចក្តីថ្លែងការណ៍ជាសាធារណៈនេះ ផ្អែកតាមវិធាន៥៤ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ដើម្បីជូនដំណឹងដល់សាធារណជនអំពីសេចក្តីសម្រេច របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ អំពីបណ្តឹងឧទ្ធរណ៍នានាក្នុងរឿងក្តីប្រឆាំងនឹង មាស មុត (សំណុំរឿង ០០៣)។

ផ្ទុយទៅនឹងសេចក្តីរាយការណ៍សារព័ត៌មានមួយចំនួន *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* របស់អង្គបុរេជំនុំជម្រះ ("សេចក្តីពិចារណា") *មិន*បានទម្លាក់ការចោទប្រកាន់ប្រឆាំងនឹង មាស មុត នោះឡើយ។ ហើយអង្គបុរេជំនុំជម្រះក៏*មិនបាន*សម្រេចឱ្យបញ្ឈប់រឿងក្តីនេះ មិនឲ្យបន្តទៅជំនុំជម្រះនោះដែរ។

សេចក្តីពិចារណានេះសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ភាគីក្នុងសំណុំរឿង០០៣ជំទាស់ទៅនឹងដីកាដំណោះស្រាយពីរខ្វែងគ្នារបស់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលបានចេញនៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។ ដីកាដំណោះស្រាយទាំងពីរនេះមានសេចក្តីសន្និដ្ឋានគតិយុត្តិផ្សេងគ្នា ផ្អែកលើការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតក្នុងឧក្រិដ្ឋកម្មនានា ដែលបានចោទប្រកាន់ប្រឆាំងនឹង មាស មុត។ សហចៅក្រមស៊ើបអង្កេតម្នាក់បានចោទប្រកាន់ មាស មុត ចំពោះឧក្រិដ្ឋកម្មអន្តរជាតិនៃអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ក៏ដូចជាការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជា និងហេតុដូច្នេះបានសម្រេចបញ្ជូនខ្លួន មាស មុត ទៅជំនុំជម្រះ ("ដីកាបញ្ជូនខ្លួនទៅជំនុំជម្រះ")។ សហចៅក្រមស៊ើបអង្កេតម្នាក់ទៀត បានទម្លាក់ការចោទប្រកាន់ក្នុងរឿងក្តីនេះ ដោយហេតុថាគាត់មិនចាត់ទុកថា មាស មុត ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះទេ ("ដីកាលើកលែងចោទប្រកាន់")។

អង្គបុរេជំនុំជម្រះបានប្រើពាក្យ "សេចក្តីពិចារណា" មិនមែន "សេចក្តីសម្រេច" នោះទេ ដោយហេតុថា តាមច្បាប់គ្រប់គ្រង អ.វ.ត.ក "សេចក្តីសម្រេច" តម្រូវឲ្យមានការឯកភាពពីចៅក្រម*យ៉ាង*

*ហោចណាស់បួនរូប* ក្នុងចំណោមចៅក្រមទាំងប្រាំរូបនៃអង្គបុរេជំនុំជម្រះ។ លក្ខខណ្ឌតម្រូវនេះត្រូវបានគេស្គាល់ថាជា "សំឡេងភាគច្រើនលើសលុប"។

ចៅក្រមទាំងប្រាំរូបនៃអង្គបុរេជំនុំជម្រះពិតជាបានយល់ព្រមជាឯកច្ឆ័ន្ទថា (i) បណ្ដឹងឧទ្ធរណ៍របស់ មាស មុត មិនអាចទទួលយកបាន (ii) បណ្ដឹងឧទ្ធរណ៍ដាច់ដោយឡែកពីគ្នារបស់សហព្រះរាជអាជ្ញាទាំងពីរអាចទទួលយកបាន (iii) ការព្រមព្រៀងគ្នារបស់សហចៅក្រមស៊ើបអង្កេតទាំងពីរក្នុងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា គឺជាការខុសច្បាប់ អនុលោមតាមក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក (iv) *មិនមានសំឡេងភាគច្រើនលើសលុប* ដើម្បីចេញសេចក្ដីសម្រេចមួយដោយផ្អែកលើសំអាងហេតុរួម អំពីថាតើត្រូវតម្កល់ ឬត្រូវច្រានចោល ដីកាដំណោះស្រាយណាមួយ ឬដីកាដំណោះស្រាយទាំងពីរនោះឡើយ។ ហេតុដូច្នេះ ចៅក្រមបីរូបបានសម្រេចថា ទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះនិងទាំងដីកាលើកលែងចោទប្រកាន់មានសុពលភាពដូចគ្នា ហើយចៅក្រមពីររូបទៀតសម្រេចថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ហើយដីកាលើកលែងចោទប្រកាន់ទុកជាមោឃៈ និងគ្មានសុពលភាព។

ដោយហេតុថាចៅក្រមទាំងប្រាំរូបបានឯកភាពជាឯកច្ឆ័ន្ទថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ដូច្នេះបំពេញតាមលក្ខខណ្ឌតម្រូវសំឡេងភាគច្រើនលើសលុប ហើយចៅក្រមពីររូបនៃអង្គបុរេជំនុំជម្រះបានសម្រេចបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះមកពិនិត្យនោះ សំណុំរឿង ០០៣ ត្រូវតែបន្តទៅជំនុំជម្រះ។ ដើម្បីអនុវត្តសេចក្ដីសម្រេច*តាមព្រឹត្តន័យ*ជាឯកច្ឆ័ន្ទរបស់ អង្គបុរេជំនុំជម្រះ ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព សហព្រះរាជអាជ្ញាអន្តរជាតិនឹងស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត ដែលទទួលបានការជូន ដំណឹងអំពីសេចក្ដីពិចារណានេះ បំពេញកិច្ចអនុលោមតាមវិធានផ្ទៃក្នុង និងបញ្ជូនសំណុំរឿងនេះទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីចាប់ផ្ដើមការជំនុំជម្រះ មាស មុត ដោយកត់សម្គាល់ផងដែរថា វិធានផ្ទៃក្នុងអនុញ្ញាតឱ្យចៅក្រមម្នាក់បំពេញកិច្ចស្របច្បាប់តែម្នាក់ឯងដើម្បីបញ្ជូនសំណុំរឿងនេះ និងប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូងឲ្យទទួលយករឿងក្ដីនេះមកពិនិត្យ៕

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន
# របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹង
# ជនត្រូវចោទ មាស មុត ក្នុងសំណុំរឿងលេខ០០៣

យោងតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សហព្រះរាជអាជ្ញាជាតិ សូមធ្វើសេចក្តីប្រកាសព័ត៌មានជាសាធារណៈ ទាក់ទងទៅនឹងជនត្រូវចោទ មាស មុត ក្នុងសំណុំរឿងលេខ០០៣ ដូចខាងក្រោម៖

កាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿងលេខ ០០៣។ នៅក្នុងសេចក្តីសម្រេចខាងលើនេះ អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទ៖ (ដកស្រង់ផ្នែកពាក់ព័ន្ធ)

ប្រកាស ថាការចេញដីកាដំណោះស្រាយពីរ ដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត **គឺជាការខុសច្បាប់ ដោយរំលោភទៅលើក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។**

អនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

លើសពីនេះ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ ដែលមានចំនួន ៣រូប ក្នុងចំណោមចៅក្រមអង្គបុរេជំនុំជម្រះទាំងអស់ចំនួន ៥រូប បានសម្រេចបញ្ជូនសំណុំរឿងលេខ ០០៣ ដែលមាន មាស មុត ជាជនត្រូវចោទ ទៅតម្កល់ទុកនៅបណ្ណសារនៃ អ.វ.ត.ក។ ចំណែកឯចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ដែលមានចំនួន ២ រូប ក្នុងចំណោមចៅក្រមអង្គបុរេជំនុំជម្រះទាំងអស់ចំនួន ៥ រូប បានយល់ឃើញថា ដីកាលើកលែងចោទប្រកាន់ត្រូវទុកជាមោឃៈ និងតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿងលេខ ០០៣។

សហព្រះរាជអាជ្ញាជាតិសង្កេតឃើញថា ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺខុសច្បាប់ ស្របតាមអំណាចសាលដីការបស់អង្គបុរេជំនុំជម្រះ ដែលបានប្រកាសថា "**ការចេញដីកាដំណោះស្រាយពីរ ដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុសច្បាប់ ដោយរំលោភទៅលើក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក**"។

សហព្រះរាជអាជ្ញាជាតិ កត់សម្គាល់ឃើញថា នៅក្នុងសេចក្តីសម្រេចដោយសម្លេងឯកច្ឆ័ន្ទខាងលើរបស់ខ្លួន ពាក់ព័ន្ធនឹងជនត្រូវចោទ **មាស មុត** អង្គបុរេជំនុំជម្រះបានបង្គាប់ឲ្យក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីនានា អនុលោមតាមវិធាន ៧៧ (១៤) នៃវិធានផ្ទៃក្នុង។

ទោះបីជាយ៉ាងណាក៏ដោយ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង ត្រូវទទួលយកសំណុំរឿងលេខ០០៣ មកពិនិត្យដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង។ ចំណែកឯចៅក្រមជាតិទាំងបីរូបនៃអង្គបុរេជំនុំជម្រះ បានសម្រេចបញ្ជូនសំណុំរឿងលេខ ០០៣ ដែលមាន មាស មុត ជាជនត្រូវចោទ ទៅតម្កល់ទុកនៅបណ្ណសារនៃ អ.វ.ត.ក។

សហព្រះរាជអាជ្ញាជាតិ សូមធ្វើការកត់សម្គាល់ផងដែរទាក់ទងនឹងសំណុំរឿងលេខ ០០៤/២ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះ ដោយយោងតាមសេចក្តីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ គឺ ចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូង បានគូសបញ្ជាក់ថា នឹងពុំមានការជំនុំជម្រះក្តីលើសំណុំរឿង ០០៤/២ ពាក់ព័ន្ធ អោ អាន នៅពេលនេះ ឬនៅពេលអនាគតឡើយ៕


ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh